# ល្បើកធម្មតា

## ក្បួនចៅចិន

INSTITUT BOUDDHIQUE

LIBRARY
BUDDHIST INSTITUTE
៧៤.
០០
www.budinst.gov.kh

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ស្រុង ចាន់ណា** ម្ចាស់គេហទំព័រ៥០០០ឆ្នាំ

សូមគោរពថ្លែងអំណរគុណចំពោះ

**លោកវេជ្ជបណ្ឌិត ខ្មៅ ឃុនសំរ៉ង** ជាប្រធាន

**មូលនិធិខ្មែរសម្រាប់ការសិក្សា** www.ceefoundation.org

និង **ករុណាខ្មែរ** www.karunacambodia.org

ដែលបានអនុញ្ញាតដល់គេហទំព័រ៥០០០ឆ្នាំ

យកសៀវភៅនេះមកដាក់ផ្សាយបន្តជាធម្មទាន

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ ។

បណ្ណាល័យអេឡិចត្រូនិចខ្មែរ
eLibrary of Cambodia
www.elibraryofcambodia.org

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។


សូមថ្លែងអំណរគុណដល់
**អង្គការរីស្សូ កូសី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។


Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.


A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.


www.budinst.gov.kh       www.elibraryofcambodia.org

# BONS CONSEILS

## AUX SINO-CAMBODGIENS

POÉME COMPOSÉ

PAR

**ING KHÉNG**

Cette Publication a reçu l'approbation du Conseil des Ministres

et des deux Chefs de Secte

**Deuxième Édition**

PHNOM-PENH

Édition de l'Institut Bouddhique

1958

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org

# ល្បើកទួណ្នាងក្ងួងចៅចិន

## កាព្យពាក្យ ៧

---

ស្រុកស្ពានន៍នៅថ្ងៃប្រាំបីកើត ខែស្រាពណ៍ខាន៍
ទ្វិតបឆស័ក ពីរពាន់បួនរយបិតសិបជាក់ មានថ្នាក់
ប្រាំពីរជាអរិសាន ៗ ថ្ងៃត្រិស្ដសកពដ់ជប់ប្រាំបី ខែ
អ៊ិតឆ្នាំថ្មីជាប្រមាណ មួយពាន់ប្រាំបួនរយមិនស្មាន
សេសខានសាមសិបបួនស្រា ៗ អហំនាម “ខ” ផ្សំ
ស្រៈ “អេ” តួ “ន៍” បន្ថែមបុន៍អក្សរ ត្រកូលហៅអ៊ិន៍ជា
ពង្សា មាតាបិតាសន្តតមក ៗ ជីតាទួតលួតជាតិចិនចៅ
បានចូលមកនៅសូមគោនជ្រក ក្រោមម្លប់ព្រះចៅចម
គោកធ្លុក ប្រោសប្រាណឲ្យជ្រកក្រោមបារមី ៗ ក្នុង

www.budinst.gov.kh www.elibraryofcambodia.org

ក្រុងខេមរៈកម្ពុជា យូរយាបង្កើតបុត្រា.ត្រី ដំណាតៗ

រៀងជាតិ កើតចៅប្រុសស្រីតវង្សឆ្ងាយ ៗ ដកបវេង

មកដល់ខ្លួនខ្ញុំ ព្រះគុណធ្ងន់ពុំអាចអធិប្បាយ ប្រោស

ប្រាណឲ្យបាននៅស្រុកកាយ ផាតិបិនទាំងឡាយ

តាំងពីមុន ៗ ហេតុនេះខ្ញុំសូមពោលថ្វាថ្វៃន សំដែង

រំពឹកទឹកដល់គុណ ព្រះរត្នត្រ័យថ្វៃជាមុន នូវគុណ

មាតានឹងបិតា ៗ នូវគុណសម្តេចព្រះទ្រង់ពង្ស ទ្រង់

បុត្តិអំណាចនាលោកា គ្រងកម្ពុជាមានបេស្តា ថ្វៃថ្វា

បំឡែកក្ដុកមហាជន ៗ ព្រមទាំងអស់លោករដ្ឋមន្ត្រី

ត្រួតការផែនដីគ្រប់ដំបន់ អាណាខេត្តស្រុកឃុំវេ

ពាន់ ព្ទលានកិត្តិយសខ្ពស់អនេក ៗ ទ្រង់ដុសខាត់

ពុទ្ធសាសនា ឲ្យបានភ្លឺថ្វាជាមផ្អែក ទំនុកបំរុង

www.budinst.gov.kh www.elibraryofcambodia.org

ទ្រង់ចាត់ចែក ចំណែកចំណោះខាងសាសនា ។ ដល់
បណ្ដារាស្ត្រទាំងប្រទេស ពុំមានសល់សេសខេត្រ
ស្រុកណា ក្នុងកម្ពុជារាជសីមា ឲ្យកើតបញ្ញា ទាំងប្រុស
ស្រី ៗ ទ្រង់តាំងបង្កើតនូវសាលា ព្រះរាជបណ្ណាល័យ
ជាថ្មី តាំងលោកអ្នកប្រាជ្ញប្រែបាលី ឲ្យបានសេចក្ដី
ជាពាក្យខ្មែរ ៗ ទើបយើងរាល់គ្នាបានជ្រះថ្លា ក្នុងពុទ្ធ-
សាសនាតាមនោះដែរ ព្រះគុណមហាធ្ងន់ដូចសុមេរុ
ប្រាប់ប្រែសេចក្ដីស្គាល់ខុសត្រូវ ៗ សព្វគ្រប់អត្ថគ្មាន
បន្ទោះ ក្រមុំកម្លោះចាស់សក់ស្កូវ មិនថារូបណាចេះតែ
ត្រូវ ជម្រូវឲ្យរៀនមានគ្រប់បែប ៗ ទាំងភេទសមណៈ
ភិក្ខុសាមណេរ បាតិមោក្ខពាក្យប្រែជាសង្ខេប អនា-
គារវិន័យមានបទបែប សង្ខេបពិស្ដារតាមទំនើង

www.budinst.gov.kh www.elibraryofcambodia.org

ឯភេទគ្រហស្ថក៏មានគ្រប់ ក្រោមម្លប់សាសនាពួកអស់
យើង គឺហាបដិបត្តិហាត់ចុះដើង ស្រុកគេស្រុកយើង
សូត្រត្រូវគ្នា ៗ នឹងធម៌ឯទៀតជាច្រើនកង ព្រះពជបំ-
ណាច់គាបធានា ពោះពុម្ពផ្សាយឲ្យយើងកល់គ្នា នាំគ្នា
ប្រតិបត្តិត្រង់តាមផ្លូវ ៗ គន្ធព្រះពុទ្ធសាសនា មិន
ឲ្យសាក់ខុសជាត្រូវ ដោយផ្ដាយព្រោះធ្លាប់ពីម៉ែឪ
ត្រង់ណាដែលត្រូវ ៗ កាន់យក ៗ ត្រង់ណាដែល
ខុសជម្រះចោល មិនបៀលប្រមូលមៅតែយក ទាំង
ខុសទាំងត្រូវមិនរើរក ជាប់មកជាកេរ្តិ៍ពីដូនតា ៗ
បិដកទាំង ៣ កំពុងពោះ មួយបប់មានឈ្មោះបមាតិ-
កា ព្រះសូត្រវិន័យអភិធម្ម ទ្រង់ព្រះសទ្ធាបាយ
រាជទ្រព្យ ៗ ទំនុកបំរុងជួយសាសនា បើមានឈ្មោះ

www.budinst.gov.kh www.elibraryofcambodia.org

ណាជាវមួយចប់ ដំឡៃពីររយហាសិបគ្រប់ មួយចប់

មានមួយរយដប់ក្បាល ៗ សៀវភៅយ៉ាងក្រាស់ក្រ-

ចះថា អ្នកប្រាជ្ញរចនាយ៉ាំងវិសាល វិសេសស្អាត

បែសគួរត្រអាល មួយក្បាលប្រាំថ្ងៃមើលមិនចប់ ៗ

សៀវភៅតូចធំជាច្រើនទៀត ទីងធ្ងៀតរៀបរាប់មិន

គ្រប់សព្វ គ្រប់សាស្នដែលធ្លាស់គេមិនស្អប់ គេចូល

សេពគប់ខំសិក្សា ៗ រៀនធ្វើទានសីលចេះចំណាន

គេបានឡើងកាន់វិបស្សនា សមាធិចិត្តជាឯកគ្គតា

បញ្ញាបាក់ផុះលុះកម្មដ្ឋាន ៗ មិនថាសាស្នណាជា

សាស្នណា អ្នកមានប្រាជ្ញាគេរាប់អាន តែអ្នកល្ងង់

ខ្លៅនៅប្រមាណ ប្រមាថពោលស្មានមិនខានឈប់ ៗ

ថាធមិក្លែងក្លាយខុសបុរាណ គ្មានបានពិនិត្យឲ្យសព្វ

www.budinst.gov.kh www.elibraryofcambodia.org

គ្រប់ ទោសៈមោហៈមកខ្លាំងខ្លប់ ដូចយប់នឹកឥតឥត

សំគាល់ ៗ ត្រឹមតែសីលដប់ពីដូនតា នព្វគុំព្វាមិន

ទាន់ស្គាល់ ជាតរូបកាន់ប្រាក់គ្មានទើសទាល់ មិន

ដែលពិតាល់ថាសីលតាស់ ៗ សិក្ខាពីររយម្ភៃប្រាំពិល

ថាខ្ជិលបង់ដឹងព្រោះច្រើនណាស់ បួសព្រោងលេង ៗ

បែរក្រឡាស់ ធម៌ណាដែលច្បាស់ថាធម៌ថ្មី ៗ គាគា-

វិន័យយកកស ស្តេចមន្ត្រីស្ត្រីទាំងប្រុសស្រី ជា

ធម៌សម្រាប់គ្រប់ជាតិ គប្បីស្គាល់ច្បាស់លះអវិជ្ជា ៗ

សេចក្ដីខ្លៅល្ងង់ខ្វង់គិះដៀល ជំនៀលដល់ពួកពាល

ពាលា ឯពាលគឺខ្លៅគ្មានវិជ្ជា ធ្វើតាមតែគ្នាតៗមក ៗ

មិនថារូបណាជារូបណា អ្នកមានបញ្ញាគួររិះរក ហោល

ខុសយកត្រូវប្រមូលមក ស្វែងរកផ្លូវល្អកំដរកាយ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំបាទសូមទោសអស់លោកអ្នក កុំបីអន់អាក់គិត ជិនណាយ ថាខ្ញុំប្រដៅលោកទាំងឡាយ ជាតិខ្មែរស្រុកអាយមិនមែនទេ ។ តែខ្ញុំមានចិត្តគិតសង្វេគដល់ជាតិខ្ញុំពេកដោយរិះរេ កូនចិនចៅចិនទាំងយើងគេ ហេតុបុណ្យបុព្វបានមកកប់ ។ ក្នុងល្វែងព្រះពុទ្ធសាសនា ដោយសារបានមកជ្រកក្រោមម្លប់មណ្ឌលព្រះចៅព្រះបមកត ជាម្លប់កំពូលលើផែនដីយ ហៃអស់កូនចៅចិនទាំងឡាយ ចូរស្ដាប់អធិប្បាយកាយសេចក្ដី និទានពន្យល់ជនប្រុសស្រី គប្បីតាំងចិត្តគិតឲ្យមាំ ។ គួរមានគំនិតពិចារណា គួរប្រើបញ្ញាយកមកគាំ គួរផ្សៀងត្រចៀកស្ដាប់ឲ្យមាំ ចំណាំឲ្យជាក់. ក្នុងគាថា ។ ជាពុទ្ធភាសិតពិតចំពោះ ពិរោះជាងអស់

www.budinst.gov.kh www.elibraryofcambodia.org

សាស្នាណា ៗ ក្នុងលោកទាំងបីមានទេវតា ព្រហ្មម-
នុស្សជាបរិស័ទ ៗ បើរិះសង្កេតគន់ឃើញជាក់ គួរ
ភ្ញាក់ជាក់ច្បាស់ដោយមធ្យ័ត ពុទ្ធសាសន៍បង្ហាញការ
ប្រតិបត្តិ នៃពុទ្ធបរិស័ទតាមក្បួនច្បាប់ ៗ គម្ពីរស្នឹគតិ
ឬសៀវភៅ មាននៅគរគោកទុកសម្រាប់ សម្រាយ
ស្រាយប្រែមកឲ្យស្ដាប់ សម្រាប់ប្រដៅផ្លូវត្រូវខុស ៗ
កុសលអកុសលបាបនឹងបុណ្យ ទោសគុណទុក្ខសុខ
គ្រប់ស្រីប្រុស កុំកាន់ទុច្ចរិតប្រព្រឹត្តខុស គប្បីខំដុស
ខាត់សុចរិត ៗ គួរគិតដល់គុណព្រះករុណា
ព្រះជ័យជ្រះថ្លាទ្រង់ទសពិធ ទ្រង់ឧបត្ថម្ភជួយគំនិត
រិះគិតឲ្យកើតក្បួនវិជ្ជា ៗ ដល់ពួកបណ្ដារាស្ត្រ
ស្រុកខ្មែរ ស្រុកក្រុងស្រុកស្រែផងនានា ជាទី

www.budinst.gov.kh www.elibraryofcambodia.org

សង្គ្រោះយើងពលគ្នា ឲ្យកើតវិជ្ជាទាំងពីរបាន ៗ គឺ

លោកិយៈលោកុត្តរៈ តាមបំណងយើងស្រុះស្រួលរាប់អាន

បំណោះទាំងពីរពេញបំណាន គ្រប់ប្រាណពុំនប្រាកដ

ព្រោះពរកការ ៗ គួរយល់ដល់ហេតុណាពរការណាស់

ឃើញច្បាស់ពីរឿងមុខពន្ធអារ ទាំងអ្នកជំនួញស្រែបំ-

ការ ពរការត្រូវតារយកគ្រប់មុខ ៗ ប៉ាតអំពន្ធដីស្រែ

បំការ ទឹងថ្វីពរការលោះការទុក ហាត់តែងតែកបៈឃ

រាយគ្រប់មុខ រៀបស្រុកធ្វើផ្លូវទៅវែងឆ្ងាយ ៗ បៀវត្សរ៍

មន្ត្រីសក្តិតូចធំ ក្នុងស្រុកនិគមជនទាំងឡាយ ដាំទី

ការពារកើតអន្តរាយ ឲ្យសុខសប្បាយក្នុងសីមា ៗ បើ

យើងមានទុក្ខទោសរឿងក្តី អះបមានមន្ត្រីពិចារណា

ជំនុំជម្រះតាមមាត្រា ឲ្យបានសុខាគ្រប់រូបកាយ ៗ

www.budinst.gov.kh www.elibraryofcambodia.org

បើមានពួកចោរប្លន់លុកប្លន់ ទ្រព្យធនអ្នកស្រុកផង

ទាំងឡាយ គាបានប៉ូលិសលោកទៅហាយ ខ្លះ

ខ្លាយស៊ើបចាប់តាចោរខ្លាំង ៗ យកខ្លួនមកធ្វើទោស

ផ្ទនា ឲ្យរាំងចាលពេញកំឡាំង ឲ្យយើងបានសុខ

នីរទុក្ខ ទូទាំងការណាខែត្រព្រះអង្គ ៗ ប៉ុន្តែបើមាន

ឈ្មោះអ្នកណា ជ្រះថ្លាបួសកាន់ភេទជាសង្ឃ ភិក្ខុ

សាមណេរតាមបំណង ទ្រទ្រង់ព្រះពុទ្ធសាសនា ៗ

គ្រប់វត្តនានាក្នុងខែត្រខណ្ឌ រាប់ពាន់បានបួសណារាជ-

ការ សូមបញ្ញបដិញ្ញាណសង្ឃដីកា រាជការអនុញ្ញាត

ឲ្យតាមចិត្ត ៗ លើកលែងលោះបោលប្រាក់ពន្ធដារ

រាជការមិនយកដោយគណិត ដល់ពួកអ្នកបួសជា

បព្វជិត ហៅភិក្ខុពិតឬសាមណេរ ៗ ដើម្បីសង្គ្រោះ

www.budinst.gov.kh www.elibraryofcambodia.org

ដល់ពួកជន ព្រះគុណមហាធ្ងន់ដូចឪម៉ែ លះបង់កេដ-
ទ្រព្យផ្គាប់ឲ្យតែ ជាតិកូនចិនខ្មែររៀនវិជ្ជា ៗ ដោយ
សារបួសរៀនមានក្បួនច្បាប់ សម្រាប់សាសនាផង
នានា ទ្រទ្រង់តាមភេទនៃបព្វជ្ជា ក្នុងពេជកាពម្ចាស់
ផែនដីៗ ទ្រង់បង់ជំនើនព្រះសាសនា ស៊ូលោះពន្ធដារ
ការបុរី គួរតែបួសហើយរំឃ្លាតខ្ចី រៀនសូត្របាលី
ទីនសម្រាយ ៗ ឲ្យបានដឹងជានព្រះសាសនា បញ្ញត្តិ
យ៉ាំងណាខំខ្វល់ខ្វាយ ឲ្យបានដឹងច្បាស់អត្ថបរិយាយ
នាំទាំងឡាយប្រៀនប្រដៅ ៗ ទើបអាច
ប្រតិបត្តិត្រឹមត្រូវបាន កុំធ្វើស្មានៗតាមកំឡៅ វិន័យ
ធម៌គាថាការពាក់ជ្រៅ នៅក្នុងបិដកទាំងបីស្រាប់ ៗ
ដូចបានសំដែងហើយខាងមុន ព្រះគុណផែនដីរៀប

www.budinst.gov.kh www.elibraryofcambodia.org

សម្រាប់ សម្រេចសេចក្ដីទុកជាច្បាប់ សម្រាប់បំរុងព្រះ
សាសនា ។ ដើម្បីសមមិនរៀនពេញអាក្រក់ ហាក់ដូច
កុហកផងសកាដការ ចំណេកចំណោគណោះហោលគន្ធារ
ចាំបួសសិក្សាធម៌វិន័យ ។ ស្គាល់ខុសស្គាល់ត្រូវតាម
ពុទ្ធដីកា កាន់ព្រឹត្យសិក្ខាឲ្យរឹងរ៉ៃ បើបួសលេងៗ ឥត
ក្រែងភ័យ គ្មានរៀនវិន័យឲ្យចាំបាន ។ សាសនា
ប្រែប្រាពាក្យប្រដៅ បើបេះតែបើពោលប្រមាណ
ធ្វើម្ដេចនឹងត្រូវតាមសំអាង ព្រោះស្គាល់មិនបានអត្ថ
បាលី ។ បើលោកសំដែងក្នុងបិដក ពេញព្រាយ
សំឡាប់មុខខ្ញុំខ្ញី តិះដៀលពោលត្រះថាធម៌អ្វី ជាធម៌
ថ្មីៗ ទើបនឹងកើត ។ មិនមែនព្រះទេអស់ក្នុងពៅ
ប្ងរសៅច្បាប់ច្បាស់ទំនុកឯង ទីក្រុងក្នុងពេញរាំង

www.budinst.gov.kh www.elibraryofcambodia.org

ចរិញ្ចូន ខាងមុខនោះឯងឋណ្ណាល័យ ។ ជាជួរទីន សាលាបាលី លោករដ្ឋមន្ត្រីត្រូវតែ អ្នកប្រាជ្ញ ប្រែធម៌តែសព្វថ្ងៃ ព្រះចៅក្រុងក្រែទ្រង់អនុញ្ញាត ។ ឲ្យរដ្ឋមន្ត្រីស្តីការឃាំង ហាយប្រាកព្រះឃាំងតាំង ក្បួនខ្នាត បង្កតាំងបទុកជាអាទិ៍ សង្វាតជួយគាំពារ សាសនា ។ អាណិតជាតិយើងដែលល្ងង់ខ្លៅ លិចលង់ផុងនៅកងអវិជ្ជា អ្នកប្រាជ្ញជាន់ដើមមាន បញ្ញា តែជាសាសនាឃៀងឃ្លាតឆ្ងាយ ។ គ ១ រៀន មកលុះឥឡូវ ព្រោះតែមិនសូវមានប្រែស្រាយ ច្រើន តែបាលីលោកចែងហាយ អស់យើងពាំងឡាយស្តាប់ មិនបាន ។ មិនបែកបញ្ញាថាគំនិត បើគិតក៏គិតដោយ ការស្មាន រៀនសូត្របេះចាំតាំងប៉ុន្មាន ថាបានបុណ្យ

www.budinst.gov.kh www.elibraryofcambodia.org

ហើយគ្រន់រៀនបប់ ៗ រៀនចាំតែមាត់ភ្ញាត់គំនិត ព្រោះគិតមិនយល់ដោយគ្រប់សព្វ ប៉ុនប៉ងយកបុណ្យគ្រន់រៀនបប់ ខ្សែខ្សបមុខក្រោយគ្មានដឹងអ្វី ៗ សំដៅយកបុណ្យគ្រន់បេះសូត្រ បាតិមោក្ខរហូតចប់បាលី តែគ្មានបានដឹងជារឿងអ្វី ពុំយល់សេចក្ដីប្រាប់សាសនា ៗ នៅក្នុងបាតិមោក្ខទាំងមូលនោះ ចំពោះបញ្ញត្តកងសិក្ខា វិន័យជាប្ញសគល់សាសនា សិក្ខាពីរយម្ភៃប្រាំពីល ៗ រៀនចប់ចាំមាត់នោះល្អណាស់ តែឲ្យដឹងច្បាស់អស់មន្ទិល សេចក្ដីសម្រាយកុំឲ្យខ្វិល ទើបអាចរមិលឃើញខុសត្រូវ ៗ ប្រតិបត្តិគ្រន់តាមក្រិត្យសិក្ខា អាចញ៉ាំងសាសនាឲ្យគ្រន់ផ្លូវ យកបុណ្យគ្រន់នេះទើបពេញត្រូវ តាមផ្លូវអដ្ឋង្គិកមគ្គ ៗ

www.budinst.gov.kh www.elibraryofcambodia.org

ទើបពេញជាស្រែបុណ្យមហាផល បរិច្ចាគទ្រព្យធន មកពឹងពាក់ ផ្ទុកក្នុងសំពៅទៅអមតៈ រួចពីអាសវៈ ចេញទៅបាន ។ ឯពួកគ្រហស្ថទោះប្រុសស្រី កើតក្នុងលោកីយទាំងប៉ុន្មាន ពេញមហាលាភធំរកក្របាន នាំប្រាណមកជួបពុទ្ធសាសន៍ ។ គួរណាស់កូនចៅទាំងឡាយអើយ កុំធ្វើកន្តើយបួរហ័ស រៀនសូត្រធម៌អាថ៌ឲ្យចាំច្បាស់ រហ័សធ្វើទានសីលភាវនា ។ គោរពកោតខ្លាចលោកអ្នកចាស់ មានវ័យក្រៃលក្រាស់ជាវុឌ្ឍា ធ្វើការបំរើសន្សំនានា កាលគ្រាធ្វើបុណ្យរួចជូនផល ។ ដល់អ្នកដ៏មានគុណទាំងឡាយ គឺម្ដាយឪពុកទុកដំកល់ អនុមោទនាយកកុសល បំ-ណែកបុណ្យផលឲ្យបានទៀត ។ សំដែងធម៌អាថ៌ឲ្យ

www.budinst.gov.kh www.elibraryofcambodia.org

គេស្តាប់ ពន្យល់តាមសព្ទពាក្យតទៀត ប្រឹងស្តាប់

យកដោយខ្លួនឯងទៀត ហើយទៀតប្រដៅចិត្តឯង

ផង ៗ ឯបញ្ញាកិរិយាតាំងជប់នេះ ជាយានជំនិះជិះ

ចំឡង ឲ្យរួចចាកចេញពីចំណង សង្សារវដ្តចងជាប់

ច្រើនជាតិ ៗ ច្រើនជាន់វណ្ណទាក់ធ្លាក់អបាយ យូរ

ឆ្ងាយទូលាយមិនអាយឃ្លាត កើតស្លាប់កប់មុនសែន

លានជាតិ ព្រោះតែមារយាទល្ងង់ខ្លៅ ៗ ពេលនេះ

គួរដឹងភ្ញាក់ខ្លួនបាន ដោយមានអ្នកប្រាជ្ញប្រៀនប្រដៅ

មិនគួរនាំគ្នាដេកតែខ្លៅ មួយមើនឹងប្រាជ្ញប្រែបរិយាយ ៗ

ពន្យល់បង្ហាញផ្លូវរៀបត្រង់ មិនចង់ចូលជិតបៀសវាង

ឆ្ងាយ គ្មានគិតអាណិតដល់រូបកាយ មិនស្តាយកំ-

ណើតជាតិនៃខ្លួន ៗ ដែលបានកើតមកជួបសាសនា

www.budinst.gov.kh www.elibraryofcambodia.org

ប្អូនលើកដការតែងបញ្ជាប់ក្បួន គម្ពីរដីកាពេញសំនួន

កុំគីផ្ទាក់ខ្លួនជាតិវេទ្ធាន ។ អសោចិ៍លើសខ្មោច

កណ្តាលព្រៃ គ្មានភ័យទឹងពោសកុងសន្តាន វៀន

សូត្រធម៌អាចិថាស្មាន ។ សីលទានផ្ញើប្រាណលើ

អាចារ្យ ។ គ្រង់ការខុសត្រូវមិនសូវគិត ប្រគល់

គំនិតលើលោកតា លោកទាញទៅដាក់ថ្នាក់ដាន់ណា

ស្រេចទឹងប្រាជ្ញាបេះតែបាន ។ ពេលស្លាប់ទៅប្រាប់

លោកអាចារ្យ ឲ្យផ្ចេបនេត្រាធ្វើកម្មដ្ឋាន នាំផ្លូវទៅ

ដាក់សួគ៌ឲ្យបាន ដល់ឋានតាក៏ដានាយទ្វារ ។

គួរឬតាកឹងកាយវេកម្ម ឈរចាំតែប្រាប់ដានមាគ៌ា

ទាំងថ្ងៃទាំងយប់គ្រប់វេលា ចាក់សោបើកទ្វារនាំដាក់

ផ្លូវ ។ មិនដឹងជាមានធម៌បែបណា អាចារ្យបេះដឹង

www.budinst.gov.kh www.elibraryofcambodia.org

នាំជម្រូវ ជម្រង់លើកដាក់ចំណាក់ផ្លូវ ឲ្យត្រូវទៅ

លើសួគ៌និព្វាន ៗ ព្រះពុទ្ធជាម្ចាស់ត្រាស់ទេសនា ថា

ឲ្យខំស្វាហាប់ធ្វើសីលទាន កាន់ក្ដីសុចរិតកុំឈ្លានពាន

ឲ្យមានសីលប្រាំនឹងកម្មបថ ៗ ប្រយ័ត្នទ្វារកាយវាចា

ចិត្ត ប្រព្រឹត្តខ្លួនឯងឲ្យហ្មត់ចត់ កតញ្ញូខន្តីក្ដីអំណត់

បានបទសប្ដំតាំងកម្មដ្ឋាន ៗ លះនីវរណៈជាសត្រូវ

នឹងផ្លូវសមាធិជាប្រធាន ឲ្យស្ងប់រម្ងាប់ចិត្តក្សេមក្សាន្ត

ទើបបានក្ដីសុខផុតទុក្ខា ៗ មិនឮថាគេធ្វើជួសបាន

នាំប្រាណទៅដាក់ឋានទេវតា ហាក់ដូចពោលជ្រួស

ហួសពុទ្ធដីកា ដូចលោកអាចារ្យបេះដាន់ព្រះ ៗ ឯគន្ថ

គម្ពីរវិសុទ្ធិមគ្គ ជាច្បាប់ដាក់លាក់ត្រឹមត្រូវណាស់

តាំងពីបុរាណគម្ពីរចាស់ មិនដែលប្ដូរផ្លាស់ចាស់ជាថ្មីៗ

www.budinst.gov.kh www.elibraryofcambodia.org

ជាក្បួនសមាធិកម្មដ្ឋាន បុរាណចារឹកជាបាលី អ្នក
ប្រាជ្ញប្រែសព្វប្រាប់សេចក្ដី ចេញពីបាលីឲ្យឃើញ
ស្ដែង ៗ ពន្យល់ដល់យើងដែលងងឹត មិនអាចនឹង
គិតឃើញខ្លួនឯង ធម៌អាថ៌លោកណា នឹងហ៊ានក្លែង
អ្នកប្រាជ្ញលោកតែងតាមគម្ពីរ ៗ ក្នុងផ្ទៃបិដកតាំងមូល
នោះ លោកបានពិគ្រោះឃើញខ្ទេចខ្ទី ដំនុំយល់
ព្រមគ្រប់ពេញទី គណៈសង្ឃពីរយល់ព្រមផង ៗ
នៃអស់កូនចៅតាំងប្រុសស្រី កុំស្ដីផ្ដេសផ្ដាសក្រែង
មានហ្មង កុំអាងប្រកួតអួតប្រឡង ជជែកម្ដង ៗ ស្មើរ
បែកស្រុក ៗ ខ្លះអ្នកធម៌ចាស់ខ្លះអ្នកថ្មី តាំងប្រុស
តាំងស្រីកើតអុកឡុក គាន់ពួកគាន់ក្រុមគ្រប់តែស្រុក
មិនចេះបានសុខមូលមាត់គ្នា ៗ សាសនាព្រះពុទ្ធតែ

www.budinst.gov.kh www.elibraryofcambodia.org

មួយអង្គ លោកសង្ឃកាន់ត្រឹត្របែកសមគ្គា ជាសក
កាន់ពួកខុសបែបគ្នា វិន័យធម្មមានតែម្យ៉ាង ៗ ចូរ
មើលគម្ពីរឲ្យប្រាកដ មានបទគាថាទុកជាអាង អ្នក
ប្រាជ្ញសំដែងបែងដោយយ៉ាង មានគាងគម្ពីរគ្រប់
មាតិកា ៗ បើនៅសង្ស័យត្រូវបញ្ជាក់ ឲ្យដឹងតាម
វគ្គគម្ពីរណា ត្រូវមើលឲ្យច្បាស់ទឹងនេត្រា កុំជាតែ
មាត់យាត់មិនស្តាប់ ៗ ឲ្យស្ទាត់បាត់ឆ្ងល់ពីនេះទៅ
ឯធម៌សៀវភៅជាក្បួនច្បាប់ រាជការអនុញ្ញាតខាងខ្លួន
ស្រាប់ ប្រថាប់ទាំងត្រាបណ្ណាល័យ ៗ ជាគោលចារឹក
ព្រះសាសនា កុំក្បួនទៅណានៅសង្ស័យ ចូរចំរៀន
សូត្រទាំងយប់ថ្ងៃ ទឹងមានទិស្ស័យក្នុងសាសនា ៗ
អនាគតកាលឯមុខគ្រាន់ ទុកជាមិនទាន់បានស្រោតា

www.budinst.gov.kh www.elibraryofcambodia.org

ទីអរិយមគ្គថ្នាក់ដាន់ណា គង់បានសុខាដាលំដាប់ ៗ
មិនបង់ខ្លួនជាតិខ្លួនកំណើត បានកើតជាមនុស្សពេញ
មានភ័ព្វ កុំឲ្យថ្លោះធ្លោយដោយសារធ្លាប់ មិនស៊ាប់
ពីព្រះរៀនធម៌ប្រែ ៗ មិនក្រពីព្រះរក្សាសីល
បើក្រព្រោះខ្ជិលមិនធ្វើស្រែ ឬខ្ជិលមិនគិតរកជួញប្រែ
គិតតែប្រទូស្តធម៌ចាស់ថ្មី ៗ អ្នកប្រាជ្ញមានគុណមាន
បញ្ញា ទសព្រហ៍ចំរៀបធម៌វិន័យ កុំអាងអួតបេះតែ
ក្នុងព្រៃ ឥតទឹកមមែខ្មាសបណ្ឌិត ៗ កុំជឿតាមពាក្យ
ពាលកំឡៅ អ្នកប្រាជ្ញប្រដៅត្រូវឲ្យគិត កុំតាមពួក
ពាលខ្លួនគំនិត ត្រូវគិតតាមប្រាជ្ញប្រែបាលី ៗ កុំគប់
ទីដ៏មនុស្សជឿអារក្ស ក្រែងធ្លាក់ទៅក្នុងអវិចី ជឿ
សរណគមន៍គុណទាំងបី សីលប្រាំ-ប្រាំបីប្រសើរ

www.budinst.gov.kh www.elibraryofcambodia.org

ណាស់ ៗ អ្នកប្រាជ្ញជាន់ណាគង់សរសើរ នេះគឺ
ជំណើរគេខ្ទង់ព្រះ កុំព្រើលទៅតាមពួកពាលមានះ
បង់ព្រះសំពះឯបាយ៉ាប ៗ ទៅពឹងអារក្សនឹងអ្នកតា
ប្រាជ្ញថាយកបុណ្យបង់រូបបាប គ្មានខ្មោចអារក្សណា
ជេះខាប ឲ្យរួចពីបាបកម្មទៅបាន ៗ ស្រេចតែនឹង
ខ្លួនទីពឹងខ្លួន កុំក្លួនប្រទូស្តដូចតិរច្ឆាន ទានសីល
សមាធិកម្មដ្ឋាន អ្នកណាគិតអានបានអ្នកនោះ ៗ
មគ្គផលមិនដែលកើតសៀម ៗ ដេកត្រៀមចាំផល
ឲ្យបានលុះ ធម៌អាថ៌សង្ស័យមិនជេះធ្លុះ តាមនេះក្រែង
នោះមិនស្រេចការ ៗ សង្ស័យនឹងធម៌ថាថ្មីចាស់
អ្នកប្រាជ្ញប្រែបញ្ជាស់មិនត្រូវការ មិនចេះយល់ព្រម
តាមអ្នកណា ភ្លេចថ្លាដើរឈ្លោះពីព្រោះខ្លៅ ៚

www.budinst.gov.kh www.elibraryofcambodia.org

គេថាឯស្តាំចាំទៅឆ្វេង សំដីអ្នកក្មេងអាងកំឡៀ
ខ្លាចហោគមិនស្តាប់ប្រាជ្ញប្រដៅ ខ្លាចគេមិនហៅ
លោកអាចារ្យ ៗ សង្ខេបបែបខ្ញុំតែប៉ុណ្ណោះ ដំណា
តីនេះសូមពណ៌នា ចំពោះកូនចៅអ្នកសិក្សា ដែល
មានប្រាជ្ញារៀនត្រង់ត្រាប់ ៗ ទាំងភេទបព្វជិតឃរា-
វាស អ្នកឈ្លាសវាងវៃសូមផ្ទៀងស្តាប់ កុំអាងតែប្រាជ្ញ
មិនខ្លាចបង្អាប់ កុំប្រែក្រឡាប់មើលងាយចាស់ ៗ កុំ
អាងខ្លួនរៀនបេះបំគ្រាន់ លោកជាន់លើគេមិនក្រែង
ខ្លះ មិនខ្លាចអំណាចអាជ្ញាព្រះ ពោលព្រាងអាង
ប្លាស់មួយសៀវភៅ ៗ គួរគិតអាណិតដល់អ្នកល្ងង់
ឃើញគ្នាលិចលង់ផុងចុះជ្រៅ គួរតែស្រោចស្រង់ផ-
ច្រង់ផ្លូវ កុំប្រានគ្នាទៅឡែកក្តៅចិត្ត ៗ ឯលោកអ្នកបេះ

www.budinst.gov.kh www.elibraryofcambodia.org

ធម៌វិន័យ គួរមានមេត្រីក្តអាណិត អាសូរដល់អ្នកខ្លៅ
ផងទៀត ជួយគិតដឹកនាំគ្នាទៅផង ៗ កុំបេះបន្តិចកំប៉ិច
ឡើង បុកឆ្នើងក្រើនខុសល្បត់ល្បង ធម្មតាអ្នក
ប្រាជ្ញខ្លាចសៅហ្មង មិនហ៊ានកន្លងបង្គាប់មាត្រា ៗ
បួសជាភិក្ខុខ្លាចអាបត្តិ វិន័យបញ្ញត្តិហាមឃាត់ណា
ប្រព្រឹត្តធ្វើតាមគ្រប់សិក្ខា ទើបបានហៅថាសង្ឃបរិ-
សុទ្ធ ៗ សាមណេរខ្លាចទោសទណ្ឌកម្ម វត្តបិតសិប
ប្រាំទីបំផុត ឈ្មោះសេក្ខិយវត្តបង្គាប់កុលបុត្រ ត្រូវ
ខំលំអុតប្រព្រឹត្តតាម ៗ គ្រហស្ថត្រូវខ្លាចដាច់សីល
ប្រាំ ឧបោសថកម្មព្រះផ្តាំហាម ដួញប្រាំកម្មបថ
កំណត់តាម កុំឲ្យមានស្នាមជុះធ្លាយឡើយ ៗ ទើប
បានឈ្មោះជាពុទ្ធបរិស័ទ ទឹងនួនវិមុត្តិទៅដល់ត្រើយ

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះមានធ្វើត្រូវតាមផ្លូវហើយ នឹងបានសះស្បើយ

ពាក់ទុក្ខភ័យ ៗ តែថាកុំទ្រឹងត្រឹមទានសីល គួរ

ប្រឹងកកិលដោយមមៃ ភាវនាស្ទឹងស្ទាធ៍ស្អាតប្រពៃ

ដកចិត្តអាល័យពីត្រកត ៗ វេលារក្សាសីលប្រាំបី

ត្រូវលៃពេលថ្ងៃឬពេលយប់ ពេលណាស្ងាត់ស្រួល

ចូលប្រារព្ធ តាំងចិត្តឲ្យស៊ប់ក្នុងកម្មដ្ឋាន ៗ បំណាច់

ខំលះកិច្ចកង្វល់ ប្រាថ្នាមគ្គផលសួគ៌និព្វាន បើនៅ

ស្ងៀម ៗ ធ្វើម្តេចបាន ដល់ទីក្សេមក្សាន្តដូចប្រាថ្នា ៗ

បញ្ឈប់សេចក្តីតែប៉ុណ្ណឹង កូនណាចង់ដឹងចូរសិក្សា

សាកសួរអ្នកប្រាជ្ញឲ្យច្បាស់ការ ឃើញទាស់ត្រង់

ណាតវ៉ាទៅ ៗ កុំថាដល់ច្បាប់គម្ពីរធំ សូម្បីច្បាប់

ក្រមឬកូនចៅ ពាក្យចាស់រ៉ាំងនេតិសាស្ត្រទៅ គង់

www.budinst.gov.kh www.elibraryofcambodia.org

មានប្រាប់ផ្លូវត្រូវយាត្រា ៗ ធម្មបទមង្គលវិសុទ្ធិមគ្គ ក្រែងមើលមិនជាក់គ្រប់មាតិកា ព្រោះមានអ្នកខ្លះខ្វះ អ៉ែនតា ពោលគឺបញ្ញាជាគ្រឿងធ្លុះ ៗ តែជាសូម ជ្រាបជូនបេះសិន កុំគាលសង្កិនស្តីបន្ទុះ បួលគិតមុខ ក្រោយឲ្យសព្វសុះ គង់ឃើញត្រូវខុសនៅផ្សេងគ្នា ៗ ពាក្យថាចាស់ថ្មីស្តីកំណត់ ហៅតាមសន្មតដោយវោ-ហារ សភាវៈធម៌គ្មានរូបា បានអ្វីត្រង់ណាថាថ្មី ចាស់ ៗ គ្រាន់តែជាពាក្យប្រៀនប្រដៅ ប្រាប់ផ្លូវ ក្រទៀតតមានខ្លះ ឯធម៌វិន័យរបស់ព្រះ យូរណាស់ គ្មានចាស់ទៅណាឡើយ ៗ ដូចពាក្យថាបាណាតិ-បាត យូរឆ្នាំច្រើនជាតិណាស់មកហើយ មិនដែលថ្មី ចាស់ស្លាប់មួងឡើយ នេះហើយគមតាវចាពិត ៕

www.budinst.gov.kh www.elibraryofcambodia.org

ខន្ធអាយតនៈត្រៃលក្ខណ៍បី ទាំងធម៌ដទៃគួរពិចិត្រ

សីលប្រាំ ប្រាំបីក្តីសុចរិត ជាពុទ្ធភាសិតឥតគមាន

ឆ្គង ៗ ត្រង់ពាក្យចាស់ថ្មីសំដីមនុស្ស បេះតែ

ពីរុះខុសទំនង ប្រកាន់ពួកក្រុមនាំសៅហ្មង ធ្វើខុស

គន្លងពីបុរេ ៗ ព្រះពុទ្ធជាគ្រូចាស់បុរាណ ត្រាស់

ដឹងពេញញាណមកមុនគេ មិនដែលផណ្តើមចាស់

ថ្មីទេ ហេតុម្តេចធ្វេសទ្វេមិនធ្វើតាម ៗ ឲ្យត្រូវ

តាមផ្លូវទៅនិព្វាន ដូចព្រះទ្រង់ញាណប្រទានប្រាប់

ប្រោសប្រៀនប្រដៅទុកនៅស្រាប់ គួរប្រឹងប្រញាប់

ឆាប់ឈានដើរ ៗ ឈមមុខជម្រង់ផ្លូវប្រាំបី គន្លង

ព្រះអរិយដ៏ប្រសើរ ព្រះពុទ្ធគ្រប់អង្គផ្ចង់ដំណើរ ស្តេច

តាមដំណើរផ្លូវនោះឯង ៗ ដំណើរនោះមានកាំប្រាំបី

www.budinst.gov.kh www.elibraryofcambodia.org

ព្រោះតាំងប្រុសស្រីប្តចាស់ក្មេង ឡើងបានតាំងអស់

ឥតទើសទែង ទូលាយធំធេងគ្មានចង្អៀត ៗ ឡើង

ដើររហូតផុតកពបី បានដល់បុរីថ្លៃថ្លាទៀត គឺទីនិព្វាន

គ្មានកន្លៀត កន្លែងចង្អៀតតិចតួចសោះ ៗ ឯអង្គ

ព្រាំបីនោះពុទ្ធដីកា ទ្រង់ចាត់ចូលគ្នារួមតាំងអស់ ហៅ

ថាសិក្ខាបីប៉ុណ្ណោះ គឺសីលសមាធិបញ្ញា ៗ សម្មា-

វាចាកម្មន្តា ទីអាជីវៈបីប្រការ ចាត់ចូលជាសីលៈ-

សិក្ខា តាមព្រះពុទ្ធដីកាទ្រង់ពន្យល់ ៗ ឯវាយាមោ

ទីសតិ ទីសមាធិបិត្តដំកល់ សម្រឹងទន្ទឹងរង់មគ្គ

ផល ប្រមូលកុសលតាំងប៉ុន្មាន ៗ ចាត់ជាសមាធិ-

សិក្ខា តាមដោយពុទ្ធដីកាទ្រង់ទូន្មាន ប្រដៅសព្វ

សត្វច្រើនកោដិលាន បានសួគ៌និព្វានរាប់មិនអស់ ៗ

www.budinst.gov.kh www.elibraryofcambodia.org

សម្មាទិដ្ឋិសង្កប្បោ ជាទីក្រោយមានកំពស់ កំពូល
វិសេសលើសទាំងអស់ នោះឈ្មោះបញ្ញាសិក្ខាស្ដែង
ៗ ឯអង្គប្រាំបីត្រៃសិក្ខា ដូចបានពណ៌នាមកនេះឯង
ជាធម៌សម្រាប់ប្រាប់គន្លង កុំឲ្យវង្វេងពីនិព្វាន ៗ
ត្រង់ធម៌ចាស់ថ្មីសំដីក្លាយ មគ្គផលទាំងឡាយមិនដែល
បាន ព្រោះពាក្យទាំងនោះខុសបុរាណ នាំឲ្យរំខាន
ថយកំឡាំង ៗ អ្នកចេះបរិយត្តិបិដក បើពោល
កុហកគ្មានទីតាំង កាប់ពុទ្ធដីកាព្រះអរហំ ទៅសោយ
ទុក្ខខ្លាំងក្នុងអបាយ ៗ ដូចកបិលភិក្ខុជាតួយ៉ាង
ចេះហើយក្អេងក្អាងអាងបរិយាយ ញាំញីសាសនា
ឲ្យអន្តរាយ ធ្លាក់ទៅអបាយកាយអប្រិយ ៗ ឯលោក
អ្នកចេះខាងកម្មដ្ឋាន ដែលបានដល់ឈានជាលោកិយ

www.budinst.gov.kh www.elibraryofcambodia.org

គន់តែធ្លាក់ខ្លួនទៅអវិចី ព្រោះគឺប្រព្រឹត្តិខុសកន្លង ៗ

ដូចយ៉ាងទេវទត្តស្លាត់បំណាប់ ចូលពេញឈានផាប់

ឃើញច្បាស់ទៃង បំរើនបុគ្គាអស្ចារ្យស្តែង ខំលើកខ្លួន

ឯងធ្វើជាព្រះ ៗ ថ្លែងរឿងនេះមកដោយសង្ខេប

គ្រាន់តែជាបែបឲ្យឃើញច្បាស់ ជានសួគិនិញានព្រះ

ទ្រង់ត្រាស់ ជាច្បាស់បានព្រោះផ្លូវនេះឯង ៗ ផ្លូវនេះ

ឈ្មោះជាមជ្ឈិមា បដិបទាតាមអត្ថថែង ជាផ្លូវត្រង់ពិត

ឥតមានវង្វេង ឯកឯងទីទៃពីផ្លូវវង្វេង ៗ បញ្ចប់ត្រឹម

នេះតាមវេលា ខ្ញុំមាននាមាឈ្មោះអ៊ិងខេង រីមាតា

ខ្ញុំនាមឈ្មោះអេង ស្លាបានពីក្មេងលុះសព្វថ្ងៃ ៗ បិតា

ខ្ញុំនាមឈ្មោះអ៊ិង-ស៊ុន កាលពីសៀមមុនធ្វើក្បៃ

នៅដែនសៀមរាបតាមសម័យ លោកក្ស័យជន្មាជា

www.budinst.gov.kh www.elibraryofcambodia.org

យូរឆ្នាំ ៗ នៅតែអ្នកម្ដាយមេម៉ាយចាស់ ផងរោគ
ណាស់រោគប្រចាំ ខ្ញុំខំសង្វាតស្វែងរកថ្នាំ ថែទាំកែ
រោគនៃមាតា ៗ ថ្នាំទិព្វឱសថគឺកម្មដ្ឋាន លំអាន
សមថៈវិបស្សនា ព្យាយាមរាប់ខ្យល់អានាបា ក្នុង
វ័យបច្ឆិមាជាប្រក្រតី ៗ ជាទីតបគុណដល់មាតា
បិតាដែលចូលកពលោកិយ សូមឲ្យលោកបានឋានសិរី
ដោយបុញ្ញរាសីនៃធម្មទាន ៗ ខ្ញុំខំប្រឹងតែងច្បាប់
ប្រដៅ កូនចៅចិននេះទុកជាស្ពាន ចំឡងពួកអ្នក
ដែលឈ្លានពាន ឲ្យមានសទ្ធាជឿកម្មផល ៗ ទាន
សីលភាវនាពល់គ្នាឡើង ដំកើងសាសនាលើកដំកល់
ប្រានកាត់មោហៈអកុសល បានដល់សទ្ធានិងសីលា ៗ
សុតៈចាគៈតាមលំអាន ឯបរិយោសានគឺបញ្ញា តាំង

www.budinst.gov.kh www.elibraryofcambodia.org

ប្រាំប្រចាំគ្រប់វង្សា សាសនានឹងកើតរុងរឿងបាន ។
គ្រប់គ្រាន់ប្រាំពាន់ព្រះវស្សា ត្រចះជ្រះថ្លាដូចសូរិ-
ឆាន់ កណ្ដាលវេហាអាកាសស្ថាន ឥតមានពពក
មកបាំងបិទ ។ ក្នុងទីបំផុតពាក្យកាព្យ ខ្ញុំសូមប្រា-
ថ្នាឲ្យមានចិត្ត ស្អប់ខ្ពើមបៀសវាងផ្លូវទុច្ចរិត ប្រព្រឹត្ត
សុចរិតរៀងរាល់ជាតិ ។ សូមឲ្យប្រកបដោយបញ្ញា
ចេះដឹងធម៌វិថិការក្សេនខ្នាត វាងវែងអាបក្នុងពួក
ញាតិ ជាជាតិត្រកូលអម្បូរខ្ពស់ ។ នៅក្នុងព្រះពុទ្ធ-
សាសនា បានស្ដាប់ពុទ្ធដីកាពាក្យពីរោះ សូមឲ្យខ្ញុំ
បានដល់ឋានខ្ពស់ បំពោះនិព្វានតាមបារមី ។ ព្រម
ទាំងលោកអ្នកដែលទស្សនា ឬបានសិក្សាតាមសេចក្ដី
សៀវភៅល្បើកនេះទាំងប្រុសស្រី សូមសុខសិរីគ្រប់

www.budinst.gov.kh www.elibraryofcambodia.org

ប្រការ ៗ ម្យ៉ាងទៀតសូមជូនកុសលបុណ្យ ដល់អ្នកមានគុណធ្ងន់ថ្ងៃថ្កា ព្រមទាំងសព្វសត្វទាំងទេវតា ឲ្យបានសុខាដូចបំណង ៗ មួយទៀតសូមថ្វាយជូនរាជ-ការ មានព្រះករុណាជាម្ចាស់ អគ្គប្រមុខទ្រង់គ្រប់គ្រង មន្ត្រីរាស្ត្រផងគ្រប់កន្លែង ៗ សូមបានប្រកបឡើងសក្តិបុណ្យ វិសេសជាងមុនខ្ពស់បំពេញ មានឫទ្ធិអំណាចតាមត្រាមដែន រក្សាដំណែងអន្លុងថ្ងៃ ៗ សំដែងមិនបានជាគ្រប់សព្វ សន្មតជាចប់ពាក្យតែខពន្យល់កូនចៅជាបច្ច័យ តាមកាលសម័យចប់ ឯរ ៗ

ចប់ ល្បើកទូន្មានកូនចៅចិន ។

www.budinst.gov.kh www.elibraryofcambodia.org

រោងពុម្ព តាភាសេ១ ០១១៦

www.budinst.gov.kh www.elibraryofcambodia.org

មហោរិធី ព្រះកាទ នភេក្ខុ